ACCESS 2
Sustainable quality services for all

Australian Aid

ព្រឹត្តិបត្រព័ត៌មានខេត្ត

ACCESS 2 ក្នុងខេត្តសៀមរាប

កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២

ព័ត៌មានសង្ខេបអំពីខេត្តសៀមរាប

២៥%
នៃស្ត្រីធ្លាប់ទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល [1]

២៥.៤%
នៃចំនួនប្រជាជនមានពិការភាពក្នុងទម្រង់ណាមួយ [2]

៧
ដៃគូ ACCESS 2 កំពុងធ្វើការនៅក្នុងខេត្តនេះ

[1] ស្ត្រីដែលធ្លាប់មានដៃគូ អាយុពី១៥ដល់៤៩ឆ្នាំ ធ្លាប់បានទទួលរងអំពើហិង្សាផ្នែកផ្លូវកាយ ផ្លូវភេទ ឬផ្លូវអារម្មណ៍នៅដំណាក់កាលណាមួយក្នុងជីវិតរបស់ពួកគេ។ យោងតាមការ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២។

[2] តាមរបាយការណ៍បានឱ្យដឹងថា ក្រុមប្រជាជនដែលមានអាយុចាប់ពី៥ឆ្នាំឡើងទៅ មានការលំបាកក្នុងកម្រិតណាមួយ (មានការលំបាកខ្លះ មានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានសោះ) ។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤ និងឆ្នាំ២០២១-២០២២។

តើកម្មវិធី ACCESS 2 ធ្វើអ្វីខ្លះក្នុងខេត្តសៀមរាប



កម្មវិធី ACCESS 2 កំពុងអនុវត្តសកម្មភាពនៅខេត្តសៀមរាប ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាដែលមានការសម្របសម្រួល និងបរិយាបន្នសម្រាប់អ្នកនៅរស់រានពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និងជនមានពិការភាព។ ដៃគូចំនួនប្រាំពីរ កំពុងធ្វើការនៅទូទាំងខេត្តនេះ ដោយផ្តល់សេវាជំនួយផ្នែកច្បាប់ ការគាំទ្រចិត្តសង្គម ជម្រកសុវត្ថិភាព និងសេវាបរិយាបន្នពិការភាព ដោយសហការជាមួយមន្ទីរជំនាញថ្នាក់ខេត្ត។



គណៈកម្មាធិការសម្របសម្រួលថ្នាក់ខេត្ត លើកទឹកចិត្តដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងដៃគូអនុវត្តឱ្យធ្វើការរួមគ្នា ដើម្បីធានាថាសេវាអាចតភ្ជាប់ និងបំពេញតម្រូវការទៅវិញទៅមកជាជាងដំណើរការដោយឡែកពីគ្នា។ ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត កំពុងតែអនុវត្តន៍សកម្មភាពកាន់តែជុំសជុល និងទទួលបានធនធានគាំទ្រកាន់តែប្រសើរ ខណៈក្រុមការងារឆ្លើយតប GBV កំពុងសម្របសម្រួលករណីនានានៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ ទន្ទឹមនឹងនេះ បន្ទប់ប្រឹក្សាយោបល់ GBV នៅតាមឃុំក៏កំពុងតែពង្រីកការផ្តល់សេវា ដែលផ្តល់នូវកន្លែងដែលមានសុវត្ថិភាព ងាយស្រួលសម្រាប់អ្នកនៅរស់រានមានជីវិតស្វែងរកជំនួយដែលនៅជិតលំនៅឋានរបស់ពួកគេ។

សេវាទាំងនេះ សម្រេចបាននូវមិទ្ធលដ៏សំខាន់មួយនៅដើមឆ្នាំ២០២៦ នៅពេលដែលកន្លែងផ្តល់សេវាចម្រុះ (OSSU) សម្រាប់អ្នកនៅរស់រានពី GBV ត្រូវបានដំណើរការនៅមន្ទីរពេទ្យបង្អែកខេត្ត ដែលរួមបញ្ចូលទាំងសេវាសុខាភិបាល ជំនួយផ្នែកច្បាប់ និងចិត្តសង្គម មកផ្តល់នៅកន្លែងតែមួយសម្រាប់អ្នកនៅរស់រានមានជីវិត។ ប្រទេសអូស្ត្រាលីក៏ផ្តល់ការគាំទ្រសម្រាប់ការស្តារលទ្ធភាពពលកម្មនៅមន្ទីរពេទ្យផងដែរ ដោយបំពាក់នូវបរិក្ខារថ្មីៗដែលជួយឱ្យផ្នែកព្យាបាលដោយចលនា (PT) ឆ្លើយតបតាមតម្រូវការដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស។

ការងារអាទិភាពដែលកំពុងអនុវត្តក្នុងខេត្តសៀមរាប

- អំពើហិង្សាទាក់ទងនឹងយេនឌ័រ
- បរិយាបន្នពិការភាព

លទ្ធផលសម្រេចបាននៅខេត្តសៀមរាប គិតត្រឹមខែមិថុនា ឆ្នាំ២០២៦

២០.០០៣ នាក់
ជាជនមានពិការភាព ត្រូវបានកំណត់អត្តសញ្ញាណ ក្នុងនោះ ៤.៩៣៤នាក់ បានទទួលអត្ថប្រយោជន៍ពីកញ្ចប់គ្រួសារ

៨៥ក្នុងចំណោម១០០ឃុំ
បានតែងតាំងជនមានពិការភាព ជាសមាជិក គ.ក.ន.ក

២.៣១៩ នាក់
ជាអ្នកនៅរស់រានពីGBV ទទួលបានការគាំទ្រ រួមទាំងការប្រឹក្សាយោបល់ និងតំណាងផ្នែកច្បាប់ដោយឥតគិតកម្រៃ

តើយើងធ្វើការជាមួយអ្នកណាខ្លះក្នុងខេត្តសៀមរាប

ដៃគូជារដ្ឋបាលខេត្ត

- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត
- មន្ទីរកិច្ចការនារីខេត្ត
- មន្ទីរសុខាភិបាលខេត្ត
- ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត
- ក្រុមការងារឆ្លើយតប GBV
- មូលនិធិជនពិការ
- គណៈកម្មាធិការឃុំ សង្កាត់ ទទួលបន្ទុកការងារស្ត្រី និងកុមារ (គ.ក.ន.ក)

ដៃគូអនុវត្ត និងសង្គមស៊ីវិល

- អង្គការជនពិការកម្ពុជា
- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិកម្ពុជា (CWCC)
- អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)
- អង្គការ PAfID
- អង្គការចិត្តសង្គម អន្តរវប្បធម៌កម្ពុជា (TPO)
- អង្គការ UNICEF, UNFPA និង UN Women
- អង្គការតំណាងជនមានពិការភាព (OPDs)
- វេទិកាស្ត្រីមានពិការភាព

សកម្មភាពចម្បងៗក្នុងខេត្តសៀមរាប

ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

- បំពាក់សម្ភារដល់OSSU សម្រាប់អ្នកនៅរស់រានពី GBV នៅមន្ទីរពេទ្យបង្អែកខេត្ត
- គាំទ្រជម្រកសុវត្ថិភាព ដែលធ្វើឱ្យអ្នកនៅរស់រានទទួលបានការស្នាក់នៅ អាហារ និងការប្រឹក្សាយោបល់
- បង្កើតបន្ទប់ប្រឹក្សាយោបល់ករណី GBV ដែលរក្សាការសម្ងាត់ នៅតាមឃុំចំនួន៩ ក្នុងស្រុកចំនួន៥)
- ផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតកម្រៃ ដោយអ្នកនៅរស់រានបានទទួលតំណាងផ្នែកច្បាប់ក្នុងសំណុំរឿងចំនួន ៣៤ករណី ក្នុងឆមាសទីមួយ ឆ្នាំ២០២៦
- អនុវត្តសាកល្បងគំរូទប់ស្កាត់អំពើហិង្សាក្នុងសហគមន៍ នៅក្នុងឃុំចំនួន៣ ក្នុងស្រុកពួក
- គាំទ្រក្រុមការងារឆ្លើយតប GBV ចំនួន៨ក្រុម (ថ្នាក់ខេត្ត ១ និងថ្នាក់ស្រុក ៧) និងបណ្តុះបណ្តាលសមាជិកបានចំនួន៩៧៥នាក់ អំពីការផ្តល់ប្រឹក្សា ការបញ្ជូនករណី និងការគាំទ្រផ្នែកច្បាប់

ផ្នែកបរិយាបន្នពិការភាព

- គាំទ្រការកំណត់អត្តសញ្ញាណជនមានពិការភាព ដោយក្នុងនោះបានវាយតម្លៃមនុស្សចំនួន ២០.០០៣ នាក់ ហើយជនមានពិការភាពចំនួន ១៤.៩៦៣នាក់ ទទួលបានបណ្ណសម្គាល់ជនមានពិការភាព
- ពង្រឹងក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត និងអង្គការតំណាងជនមានពិការភាព
- គាំទ្រការតែងតាំងជនមានពិការភាពជាសមាជិក គ.ក.ន.ក នៅក្នុងឃុំចំនួន៨៥

ផ្នែកការស្តារលទ្ធភាពពលកម្ម

បំពាក់បរិក្ខារដល់ផ្នែកការព្យាបាលដោយចលនានៅមន្ទីរពេទ្យបង្អែកខេត្ត ដោយបានប្រគល់ជូននូវឧបករណ៍ នៅខែមករា ឆ្នាំ២០២៦។



“កម្មវិធី ACCESS 2 បានជួយបំលែងការងារទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងខេត្តសៀមរាប ដោយពង្រឹងការសម្របសម្រួលរវាងស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអ្នកផ្តល់សេវា។ តាមរយៈវិធីសាស្ត្រដែលមានការសម្របសម្រួល និងការចូលរួមពីវិស័យពាក់ព័ន្ធនានា អ្នកនៅរស់រានមានជីវិតអាចទទួលបានការគាំទ្រទាន់ពេលវេលា គ្រប់ជ្រុងជ្រោយ និងផ្តោតលើការគាំទ្រអ្នកនៅរស់រានមានជីវិតជាស្នូល។”

លោកជំទាវ ម៉ន នី រង្សី អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប

អគារ ANINA ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

info@access2cambodia.org www.access2cambodia.org

ACCESS 2 ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងគ្រប់គ្រងដោយ Abt Global